# សេចក្តីណែនាំ

# ស្តីពី

# ការរៀបចំរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី

អនុលោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិមជ្ឈការអំណាច តួនាទី និងភារកិច្ចឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់នីមួយៗមានក្រុមប្រឹក្សាឃុំ សង្កាត់ដែលកើតឡើងតាមការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិប្រាំឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។ នៅពេលប្រកាសសុពលភាព និងចូលកាន់មុខតំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់មានកាតព្វកិច្ចធ្វើសេចក្តីរាយការណ៍សង្ខេបអំពីសមិទ្ធផលការងារសំខាន់ៗដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ និងកិច្ចការសំខាន់ៗដែលក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីត្រូវបន្តការងារក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្នុងដំណើរការនៃការរៀបចំរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ក្រសួងមហាផ្ទៃធ្វើការណែនាំដូចខាងក្រោម៖

## ១-គោលបំណង

ការរៀបចំរបាយការណ៍សង្ខេបនេះ មានគោលបំណងបូកសរុបសមិទ្ធផលការងារសំខាន់ៗរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ ព្រមទាំងកិច្ចការនានាដែលនៅសេសសល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់សម្រាប់ផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

## ២-ក្របខណ្ឌពេលវេលា

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំរបាយការណ៍សង្ខេបអំពីសមិទ្ធផលដែលបានអនុវត្តរយៈពេល៥ឆ្នាំ ដោយគិតពីថ្ងៃប្រកាសចូលកាន់មុខតំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រហូតដល់ថ្ងៃប្រកាសសុពលភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

## ៣-នីតិវិធីនៃការរៀបចំរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី

ក)-ការរៀបចំសេចក្តីព្រាងរបាយការណ៍

មេឃុំ ចៅសង្កាត់ដែលមានស្មៀនឃុំ សង្កាត់ជាជំនួយការ ត្រូវរៀបចំសេចក្តីព្រាងរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មីដូចមានទម្រង់ភ្ជាប់ជាមួយ


ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៣ e-mail: moi@interior.gov.kh web: www.interior.gov.kh

នឹងសេចក្តីណែនាំនេះ។ ការបូកសរុបរបាយការណ៍ត្រូវផ្អែកលើរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ តាមសេចក្តីណែនាំលេខ០៨៤ ស.ណ.ន. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការរៀបចំរបាយការណ៍ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

ខ)-ការពិនិត្យនិងការអនុម័តរបាយការណ៍

មេឃុំ ចៅសង្កាត់ដែលមានស្មៀនឃុំ សង្កាត់ជាជំនួយការ ត្រូវដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ នូវសេចក្តីព្រាងរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ដើម្បីពិនិត្យនិងអនុម័តឱ្យបានមុនថ្ងៃប្រកាសសុពលភាព និងចូលកាន់មុខតំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

សេចក្តីព្រាងរបាយការណ៍នេះត្រូវពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញ ឬកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់សាមី។ ក្នុងករណី ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មិនគ្រប់កូរ៉ុមសម្រាប់ដំណើរការកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់បាន សេចក្តីព្រាងរបាយការណ៍នេះត្រូវដាក់ឆ្លងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលនៅមានសុពលភាព ឬមានវត្តមានក្នុងកិច្ចប្រជុំ។

មេឃុំ ចៅសង្កាត់ត្រូវជូនដំណឹងដល់សាធារណជន និងត្រូវបង្កលក្ខណៈងាយស្រួលដល់ការចូលរួមរបស់សាធារណជន និងអ្នកពាក់ព័ន្ធនានា នៅក្នុងកិច្ចប្រជុំពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍នេះ។

បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់អនុម័តរួច របាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ឬមេឃុំ ចៅសង្កាត់ស្តីទី។

**៤-ការប្រើប្រាស់ ការផ្សព្វផ្សាយ និងការតម្កល់ទុករបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី**

មេឃុំ ចៅសង្កាត់ដែលមានស្មៀនឃុំ សង្កាត់ជាជំនួយការ ត្រូវចាត់ចែងថតចម្លងរបាយការណ៍សង្ខេបនេះរួមទាំងឧបសម្ព័ន្ធនានាសម្រាប់ចែកជូនគណៈអធិបតី សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី នៅក្នុងពិធីប្រកាសសុពលភាព និងចូលកាន់មុខតំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។ មេឃុំ ចៅសង្កាត់ ឬមេឃុំ ចៅសង្កាត់ស្តីទីអាណត្តិចាស់ត្រូវអានរបាយការណ៍សង្ខេបនេះនៅក្នុងពិធីប្រកាសសុពលភាព និងចូលកាន់មុខតំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

បន្ទាប់ពីរបាយការណ៍សង្ខេបនេះត្រូវបានចុះហត្ថលេខារួច រដ្ឋបាលឃុំ សង្កាត់ត្រូវ៖

- ផ្សព្វផ្សាយដល់សាធារណជន និងអ្នកពាក់ព័ន្ធនានា តាមរយៈការបិទផ្សាយនៅលើក្តារព័ត៌មានរបស់រដ្ឋបាលឃុំ សង្កាត់ និងមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗ
- ផ្ញើជូនរដ្ឋបាលរាជធានី ខេត្តសាមី និងរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី ចំនួន១ច្បាប់
- តម្កល់ទុកជាឯកសារនៅសាលាឃុំ សង្កាត់សាមី ចំនួន១ច្បាប់។

ស្មៀនឃុំ សង្កាត់ត្រូវរៀបចំចងក្រង និងថែរក្សាសំណុំឯកសារទាំងអស់របស់រដ្ឋបាលឃុំ សង្កាត់នៃក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ ដើម្បីធានាដល់ការបន្តនិរន្តរភាពការងារគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់នៃក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្តបន្ទាប់។

រដ្ឋបាលរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវប្រកាសផ្សព្វផ្សាយដល់រដ្ឋបាលឃុំ សង្កាត់ នូវសេចក្តីណែនាំស្តីពីការរៀបចំរបាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី។

សេចក្តីណែនាំលេខ០១៥ ស.ណ.ន. ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍សង្ខេបសម្រាប់ការផ្ទេរពីក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវទុកជានិរាករណ៍។

ទទួលបានសេចក្តីណែនាំនេះ អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ និងអង្គភាពពាក់ព័ន្ធ ត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ១០ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ
- អគ្គាធិការដ្ឋាននៃក្រសួងមហាផ្ទៃ "ដើម្បីជូនជ្រាប"
- ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត....................

ក្រុង ស្រុក ខណ្ឌ..............

រដ្ឋបាលឃុំ សង្កាត់.............

# របាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សា ឃុំ សង្កាត់អាណត្តិថ្មី

ព.ស.២៥៦...

ឆ្នាំ២០២២

# មាតិកា


សេចក្តីផ្តើម ........................................................................................................
ផ្នែកទី១សមិទ្ធផលការងាររបស់រដ្ឋបាលឃុំ សង្កាត់ ..........................................................
១.១-ស្ថិតិប្រជាពលរដ្ឋ ............................................................................................
១.២-ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក.............................................................................
១.៣-ដីកា សេចក្តីសម្រេច និងលិខិតពាក់ព័ន្ធ ...............................................................
១.៤-កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ .........................
១.៥-គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ សង្កាត់...........................................
១.៦-គម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង..............................................................
១.៧-ការអនុវត្តថវិកា ..............................................................................................
១.៨-ការគ្រប់គ្រងទ្រព្យសម្បត្តិ...................................................................................
១.៩-ការអភិវឌ្ឍសមត្ថភាព .........................................................................................
១.១០-សកម្មភាពសេវាសង្គម........................................................................................
១.១១-ការសម្រុះសម្រួលទំនាស់......................................................................................
១.១២-ការងារអគ្រានុកូលដ្ឋាន .....................................................................................
១.១៣-ការចុះឈ្មោះនិងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ......................................................
១.១៤-ការផ្តល់សេវារដ្ឋបាល ........................................................................................
១.១៥-ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ..................................................
១.១៦-ការងារសេដ្ឋកិច្ច សង្គមកិច្ច...................................................................................
១.១៧-ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន វប្បធម៌ បេតិកភណ្ឌជាតិ...........................................
១.១៨-ការងារសហការជាមួយនឹងអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ............
ផ្នែកទី២បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ......................................................................
២.១-បញ្ហាប្រឈម និងដំណោះស្រាយ ...........................................................................
២.២-យោបល់និងសំណូមពរ ..........................................................................................
ឧបសម្ព័ន្ធ៖
ឧបសម្ព័ន្ធទី១ ស្ថិតិប្រជាពលរដ្ឋ.................................................................................
ឧបសម្ព័ន្ធទី២ បញ្ជីក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ បុគ្គលិក ជនបង្គោល និងថ្នាក់ដឹកនាំភូមិ....................................................................................................
ឧបសម្ព័ន្ធទី៣ បញ្ជីគម្រោងរបស់រដ្ឋបាលឃុំ សង្កាត់ .........................................................
ឧបសម្ព័ន្ធទី៤ បញ្ជីកិច្ចសន្យានានាដែលពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ ...................................
ឧបសម្ព័ន្ធទី៥ ស្ថានភាពថវិកា និងសាច់ប្រាក់របស់រដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០២២..........................
ឧបសម្ព័ន្ធទី៦ បញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់.........................................................

( ក្បាលលិខិតរបស់រដ្ឋបាលឃុំ សង្កាត់ )

ថ្ងៃ.................... ខែ............... ឆ្នាំ................ ព.ស.២៥៦.

លេខ..............................                ............... ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២២

## របាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់
## អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី

### សេចក្តីផ្តើម

ឃុំឬសង្កាត់................គឺជាឃុំឬសង្កាត់មួយក្នុងចំណោមឃុំ សង្កាត់ទាំង...... នៃក្រុង ឬស្រុក ឬខណ្ឌ...........រាជធានីឬខេត្ត...............ដែលមានព្រំប្រទល់ខាងលិចទល់នឹង......................ខាងកើតទល់នឹង.....................ខាងជើងទល់នឹង.................. និងខាងត្បូងទល់នឹង...................។

ឃុំឬសង្កាត់................. មានផ្ទៃដីសរុប................គីឡូម៉ែត្រការេ និងមានភូមិចំនួន.......ភូមិ គឺភូមិ.........................................។

ក្នុងការអនុវត្តតួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ដែលមានក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងដោយការបោះឆ្នោតពីប្រជាពលរដ្ឋនៅមូលដ្ឋាន បានខិតខំបម្រើសេវាសាធារណៈពិសេសសេវាសាធារណៈជាមូលដ្ឋានជូនប្រជាជន ដើម្បីកិច្ចអភិវឌ្ឍមូលដ្ឋានឃុំ សង្កាត់។ ទន្ទឹមនេះ ក្នុងអំលុង៥ឆ្នាំនៃអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ពីឆ្នាំ២០១៧រហូតដល់ពេលបញ្ចប់អាណត្តិនេះ រដ្ឋបាលឃុំ សង្កាត់.............មានសមិទ្ធផលការងារសំខាន់ៗដោយសង្ខេបដូចតទៅៈ

## ផ្នែកទី១

## សមិទ្ធផលការងាររបស់រដ្ឋបាលឃុំ សង្កាត់...........

### ១.១-ស្ថិតិប្រជាពលរដ្ឋ

ក្នុងពេលបច្ចុប្បន្ននេះ ស្ថានភាពប្រជាពលរដ្ឋនៅឃុំ សង្កាត់..................មានដូចខាងក្រោមៈ

- គ្រួសារសរុបចំនួន..........គ្រួសារអេចិន្ត្រៃយ៍ចំនួន.........និងគ្រួសារបណ្តោះអាសន្នចំនួន........
- ប្រជាពលរដ្ឋសរុបចំនួន............(ស្រីចំនួន...........) ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងចំនួន.........(ស្រី.....) និងប្រជាពលរដ្ឋចំណាកស្រុកចំនួន............។

សូមមើលស្ថិតិប្រជាពលរដ្ឋលម្អិតក្នុងឧបសម្ព័ន្ធទី១នៃរបាយការណ៍នេះ។

### ១.២-ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

បច្ចុប្បន្ននេះ រដ្ឋបាលឃុំ សង្កាត់...........................មានសមាសភាពក្រុមប្រឹក្សា គណៈកម្មាធិការនានាស្មៀនឃុំ សង្កាត់ ថ្នាក់ដឹកនាំភូមិ បុគ្គលិកក្រៅក្របខណ្ឌរដ្ឋ និងអ្នកពាក់ព័ន្ធ ដែលកំពុងបម្រើការងារនៅរដ្ឋបាលឃុំ សង្កាត់ រួមមានៈ

- សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន..........(ស្រីចំនួន.......)ក្នុងនេះមានមេឃុំ ចៅសង្កាត់ ១រូប ជំទប់ទី១ចំនួន១រូប ជំទប់ទី២ចំនួន១រូប និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន.........
- សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានផ្លាស់ប្តូររយៈពេល៥ឆ្នាំ(ចាប់ពីឆ្នាំ២០១៧ដល់បច្ចុប្បន្ន)ចំនួន.............(ស្រីចំនួន.....)
- ស្មៀនឃុំ សង្កាត់ចំនួន........(ស្រី.....)
- ថ្នាក់ដឹកនាំភូមិចំនួន....(ស្រី.....) រួមមានមេភូមិចំនួន........ អនុប្រធានភូមិចំនួន...(ស្រី......) និងសមាជិកភូមិចំនួន......(ស្រី........)
- អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន......(ស្រី.......)
- ជនបង្គោលតាមដានត្រួតពិនិត្យនិងវាយតម្លៃឃុំ សង្កាត់ចំនួន...(ស្រី...) និងជនបង្គោលនានា .........
- គណៈកម្មាធិការនានានៃរដ្ឋបាលឃុំ សង្កាត់ រួមមានគណៈកម្មាធិការកសាងផែនការនិងថវិកាចំនួន.....(ស្រី....) គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ(គ.ក.ន.ក)ចំនួន.........(ស្រី....) គណៈកម្មការលទ្ធកម្មចំនួន......(ស្រី....) និងគណៈកម្មាធិការឬគណៈកម្មការ..........។

សូមមើលស្ថិតិក្រុមប្រឹក្សា និងបុគ្គលិកលម្អិតក្នុងឧបសម្ព័ន្ធទី២នៃរបាយការណ៍នេះ។

### ១.៣-ដីកា សេចក្តីសម្រេច និងលិខិតពាក់ព័ន្ធ

ក្នុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់.........បានទទួលលិខិតបទដ្ឋានគតិយុត្ត និងលិខិតមួយចំនួនពីស្ថាប័នឬអង្គភាពនានា ហើយរដ្ឋបាលឃុំ សង្កាត់បានសម្រេចដាក់ចេញនូវលិខិតបទដ្ឋានសម្រាប់អនុវត្តតួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ រួមមាន៖

- លិខិតដែលបានទទួលចំនួន......................។
- លិខិតបទដ្ឋានដែលដាក់ចេញដោយរដ្ឋបាលឃុំ សង្កាត់ ដូចជាដីកាចំនួន........ សេចក្តីសម្រេចចំនួន...............និងលិខិតរដ្ឋបាលចំនួន.............។

| |
|---|
| **សេចក្តីពន្យល់៖** ចំនួនលិខិតខាងលើនេះស្រង់ចេញពីកូឡោនទី៨ពីតារាងក្នុងចំណុច១.៣នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

### ១.៤-កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ(គ.ក.ន.ក.)

ផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ នៅក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់............បានរៀបចំកិច្ចប្រជុំសាមញ្ញ កិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងរដ្ឋបាលឃុំសង្កាត់ ឬគណៈកម្មាធិការនានា រួមមាន៖

- កិច្ចប្រជុំរបស់ក្រុមប្រឹក្សាមានកិច្ចប្រជុំសាមញ្ញចំនួន...........កិច្ចប្រជុំវិសាមញ្ញចំនួន...........និងកិច្ចប្រជុំសម្ងាត់ចំនួន...................។
- កិច្ចប្រជុំរបស់**គ.ក.ន.ក.**ចំនួន...................។

| |
|---|
| **សេចក្តីពន្យល់៖**ចំនួនកិច្ចប្រជុំខាងលើនេះអាចស្រង់ចេញពីកូឡោនទី៨នៃតារាងក្នុងចំណុច១.៤នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

## ១.៥-គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ សង្កាត់

ក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ សង្កាត់...................គម្រោងវិនិយោគដែលមានការសន្យាគាំទ្រដោយថវិការបស់រដ្ឋបាលឃុំ សង្កាត់ សរុបចំនួន......................... តម្លៃ................... ក្នុងនេះមាន៖

- ផ្នែកសេដ្ឋកិច្ចមានគម្រោងចំនួន...................... តម្លៃចំនួន.................
- ផ្នែកសង្គមកិច្ចមានគម្រោងចំនួន..................... តម្លៃចំនួន.................
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានគម្រោងចំនួន ............. តម្លៃចំនួន............
- ផ្នែកសេវារដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ មានគម្រោងចំនួន..........តម្លៃចំនួន .............។

> **សេចក្តីពន្យល់ ៖**
> - ចំនួនគម្រោងខាងលើនេះស្រង់ចេញពីកូឡោនទី១៣ពីតារាងក្នុងចំណុច១.៥នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។
> - តម្លៃគម្រោងខាងលើនេះស្រង់ចេញពីកូឡោនទី១៤ពីតារាងក្នុងចំណុច១.៥នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

## ១.៦-គម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង

ដូចគ្នានេះដែរ ចំពោះគម្រោងវិនិយោគរបស់រដ្ឋបាលឃុំ សង្កាត់............ដែលបានអនុវត្តជាក់ស្តែងក្នុងអាណត្តិរបស់ក្រុមប្រឹក្សានេះ សរុបចំនួន...................តម្លៃគម្រោងចំនួន..................ក្នុងនេះមាន៖

- ផ្នែកសេដ្ឋកិច្ចមានគម្រោងចំនួន........... តម្លៃចំនួន............
- ផ្នែកសង្គមកិច្ចមានគម្រោងចំនួន.......... តម្លៃចំនួន............
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានគម្រោងចំនួន ............. តម្លៃចំនួន....................
- ផ្នែកសេវារដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ មានគម្រោងចំនួន.........តម្លៃចំនួន ..............។

> **សេចក្តីពន្យល់÷**
> - ចំនួនគម្រោងខាងលើនេះស្រង់ចេញពីកូឡោនទី១៣ពីតារាងក្នុងចំណុច១.៦នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។
> - តម្លៃគម្រោងខាងលើនេះស្រង់ចេញពីកូឡោនទី១៤ពីតារាងក្នុងចំណុច១.៦នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

ដោយឡែក គម្រោងរបស់ឃុំ សង្កាត់២០២២ គិតថ្ងៃទី......ខែ............ឆ្នាំ២០២២ មានតម្លៃសរុប .....................................(រៀល)មានដូចខាងក្រោម៖

**ក)-គម្រោងឃុំ សង្កាត់ដែលពុំទាន់ធ្វើលទ្ធកម្ម មានតម្លៃគម្រោងសរុប................................**

ក្នុងនេះមាន៖

- គម្រោង...........................................................មានតម្លៃគម្រោង.........................
- គម្រោង...........................................................មានតម្លៃគម្រោង.........................
- គម្រោង..................................................................................................។

**ខ)-គម្រោងឃុំ សង្កាត់ដែលបានធ្វើលទ្ធកម្មរួច តែមិនទាន់បានចុះកិច្ចសន្យា មានតម្លៃគម្រោងសរុប ........................................ ក្នុងនេះមាន៖**

- គម្រោង.............................................................មានតម្លៃគម្រោង..........................
- គម្រោង.............................................................មានតម្លៃគម្រោង..........................
- គម្រោង...........................................................................................................។

**គ)-គម្រោងឃុំ សង្កាត់ដែលបានចុះកិច្ចសន្យារួច មានតម្លៃគម្រោងសរុប............................** ក្នុងនេះមាន៖

- គម្រោង.............................................................មានតម្លៃគម្រោង..........................
- គម្រោង.............................................................មានតម្លៃគម្រោង..........................
- គម្រោង...........................................................................................................។

សូមមើលស្ថានភាពគម្រោងលម្អិតក្នុងឧបសម្ព័ន្ធទី៣នៃរបាយការណ៍នេះ។

ជាមួយគ្នានេះដែរ នៅពេលបច្ចុប្បន្ននេះ មានកិច្ចសន្យាមួយចំនួនពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់ដែលមិនទាន់បានបញ្ចប់រួមមាន៖

**ក)-កិច្ចសន្យាដែលរដ្ឋបាលឃុំ សង្កាត់ជាភាគី"ក"**

- កិច្ចសន្យា........................................ដែលបានចុះកិច្ចសន្យានៅថ្ងៃទី............................ និងបញ្ចប់កិច្ចសន្យានៅថ្ងៃទី................................។
- កិច្ចសន្យា........................................ដែលបានចុះកិច្ចសន្យានៅថ្ងៃទី............................ និងបញ្ចប់កិច្ចសន្យានៅថ្ងៃទី................................។

**ខ)-កិច្ចសន្យាដែលរដ្ឋបាលឃុំ សង្កាត់ជាភាគី"ខ"**

- កិច្ចសន្យា........................................ដែលបានចុះកិច្ចសន្យានៅថ្ងៃទី............................ និងបញ្ចប់កិច្ចសន្យានៅថ្ងៃទី................................។
- កិច្ចសន្យា........................................ដែលបានចុះកិច្ចសន្យានៅថ្ងៃទី............................ និងបញ្ចប់កិច្ចសន្យានៅថ្ងៃទី................................។

សូមមើលស្ថានភាពកិច្ចសន្យាលម្អិតក្នុងឧបសម្ព័ន្ធទី៤នៃរបាយការណ៍នេះ។

### ១.៧-ការអនុវត្តថវិកា

ក្នុងអំលុង៥ឆ្នាំនៃអាណត្តិក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់.............. បានអនុវត្តថវិកាដូចខាងក្រោម៖

| ឆ្នាំ | ចំណូល(គិតលានរៀល) | | | ចំណាយ(គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | ភាគរយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
| ២០១៧ | | | | | | |
| ២០១៨ | | | | | | |
| ២០១៩ | | | | | | |
| ២០២០ | | | | | | |
| ២០២១ | | | | | | |
| **សរុប** | | | | | | |

**សេចក្តីពន្យល់៖** ទិន្នន័យខាងលើនេះ ស្រង់ចេញពីតារាងក្នុងចំណុច១.៧នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

ទន្ទឹមនេះដែរ ស្ថានភាពថវិការបស់រដ្ឋបាលឃុំ សង្កាត់.........ឆ្នាំ២០២២ គិតត្រឹមថ្ងៃទី......ខែ..... ឆ្នាំ២០២២ រួមមាន៖

ក)-ស្ថានភាពថវិកា(គិតជាលានរៀល)

- ផ្នែកចំណូល៖ អនុម័តចំនួន.............. ជាក់ស្តែងចំនួន...............និងនៅសល់ចំនួន..........
- ផ្នែកចំណាយ៖ អនុម័តចំនួន............. ជាក់ស្តែងចំនួន...............និងនៅសល់ចំនួន..........

ខ)-ស្ថានភាពសាច់ប្រាក់រដ្ឋទេយ្យបុរេប្រទាន

សាច់ប្រាក់រដ្ឋទេយ្យបុរេប្រទាន៖ ចំណូលចំនួន............................ចំណាយចំនួន................ និងនៅសល់ចំនួន..........................។

គ)-ស្ថានភាពសាច់ប្រាក់ផ្សេងៗទៀត ក្រៅពីរដ្ឋទេយ្យបុរេប្រទាន

សាច់ប្រាក់ផ្សេងៗទៀត៖ ចំណូលចំនួន..........................ចំណាយចំនួន.......................និង នៅសល់ចំនួន..............................។

ឃ)-ស្ថានភាពសាច់ប្រាក់នៅធនាគារឯកជន

- ធនាគារ.......................លេខគណនី...................ចំណូល.............ចំណាយ............... និងនៅសល់..................។
- ធនាគារ.......................លេខគណនី...................ចំណូល.............ចំណាយ............... និងនៅសល់..................។
- ធនាគារ.......................លេខគណនី...................ចំណូល.............ចំណាយ............... និងនៅសល់..................។

សូមមើលស្ថានភាពថវិកា សាច់ប្រាក់រដ្ឋទេយ្យបុរេប្រទាន និងសាច់ប្រាក់លម្អិតក្នុងឧបសម្ព័ន្ធទី៥ នៃរបាយការណ៍នេះ។

**១.៨-ការគ្រប់គ្រងទ្រព្យសម្បត្តិ**

គិតមកដល់ត្រឹមថ្ងៃទី.......ខែ.....ឆ្នាំ២០២២ រដ្ឋបាលឃុំ សង្កាត់............. មានទ្រព្យសម្បត្តិមួយចំនួនដូចជា៖

- ទ្រព្យសម្បត្តិដែលបានទិញឬទទួល(ថ្មី) ចំនួន......................
- ទ្រព្យសម្បត្តិដែលបានកាត់ចេញ ចំនួន.................................
- ទ្រព្យសម្បត្តិសរុបចំនួន....................................................។

សូមមើលស្ថានភាពទ្រព្យសម្បត្តិលម្អិតក្នុងឧបសម្ព័ន្ធទី៦នៃរបាយការណ៍នេះ។

**១.៩-ការអភិវឌ្ឍសមត្ថភាព**

ក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់......ទទួលបានការបណ្តុះបណ្តាលដែលរៀបចំដោយក្រសួង ឬស្ថាប័ន ឬអង្គការសមាគម ឬអង្គភាពពាក់ព័ន្ធចំនួន..............................វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន.....................(ស្រី.........)។

| |
|---|
| **សេចក្តីពន្យល់៖** វគ្គបណ្តុះបណ្តាលខាងលើនេះស្រង់ចេញពីកូឡោនទី៨ពីតារាងក្នុងចំណុច១.៩នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

### ១.១០-សកម្មភាពសេវាសង្គម

នៅក្នុងអំលុង៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់..........បានយកចិត្តទុកដាក់សម្របសម្រួល គាំទ្រ និងដោះស្រាយបញ្ហាសេវាសង្គមចាំបាច់មួយចំនួន សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើងតាមរយៈការងារឬសកម្មភាពសេវាសង្គមនៅឃុំ សង្កាត់ រួមមាន៖

- មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីរដ្ឋបាលឃុំ សង្កាត់ចំនួន.................
- គ្រួសារងាយរងគ្រោះគាំទ្រដោយរដ្ឋបាលឃុំ សង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) ចំនួន.........
- គ្រួសារងាយរងគ្រោះគាំទ្រដោយរដ្ឋបាលឃុំ សង្កាត់ ដែលទទួលបានទឹកស្អាតប្រើប្រាស់ចំនួន .............
- គ្រួសារងាយរងគ្រោះគាំទ្រដោយរដ្ឋបាលឃុំ សង្កាត់ ដែលទទួលបានបង្គន់អនាម័យប្រើប្រាស់ចំនួន. .............
- គ្រួសារងាយរងគ្រោះដែលរដ្ឋបាលឃុំ សង្កាត់បានចុះកំណត់អត្តសញ្ញាណចំនួន................
- ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ដែលទទួលការគាំទ្រពីរដ្ឋបាលឃុំ សង្កាត់ចំនួន..... .........។

| |
|---|
| **សេចក្តីពន្យល់៖** សេវាខាងលើនេះស្រង់ចេញពីកូឡោនទី៧និងទី៨ពីតារាងក្នុងចំណុច១.១០នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

### ១.១១-ការសម្រុះសម្រួលទំនាស់

ផ្អែកតាមតួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់.................បានខិតខំនិងយកចិត្តទុកដាក់ដោះស្រាយ ឬសម្រុះសម្រួលទំនាស់ដែលបានកើតមានឡើងក្នុងរយៈពេល៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ជាក់ស្តែង ទំនាស់មួយចំនួនត្រូវបានដោះស្រាយរួច និងទំនាស់មួយចំនួនទៀតត្រូវបានស្នើទៅស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។ ស្ថានភាពនៃការដោះស្រាយ ឬការសម្រុះសម្រួលទំនាស់ដែលបានកើតឡើងនៅក្នុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់................មានដូចខាងក្រោម៖

- ទំនាស់ដែលបានដោះស្រាយឬសម្រុះសម្រួលរួចមានចំនួន......................ករណី
- ទំនាស់ដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធមានចំនួន.............................ករណី។

| |
|---|
| **សេចក្តីពន្យល់៖**ទិន្នន័យខាងលើនេះស្រង់ចេញពីកូឡោនទី៨ពីតារាងក្នុងចំណុច១.១១នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

### ១.១២-ការងារអត្រានុកូលដ្ឋាន

ក្នុងអំលុង៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់.......បានខិតខំយកចិត្តទុកដាក់ផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាជន ស្របតាមបែបបទ នីតិវិធី និងគោលការណ៍ណែនាំរបស់ក្រសួងឬស្ថាប័នមានសមត្ថកិច្ច។ ជាក់ស្តែង ក្នុងអាណត្តិរបស់ក្រុមប្រឹក្សានេះ រដ្ឋបាលឃុំ សង្កាត់............ បានផ្តល់សេវាអត្រានុកូលដ្ឋាន រួមមាន៖

- សំបុត្រកំណើតចំនួន..............................សំបុត្របញ្ជាក់កំណើតចំនួន.........................

សេចក្ដីចម្លងសំបុត្រកំណើតចំនួន............និងសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតចំនួន.......
..........។

- សំបុត្រអាពាហ៍ពិពាហ៍ចំនួន................និងសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន........។
- សំបុត្រមរណភាពចំនួន..........................និងសេចក្ដីចម្លងសំបុត្រមរណភាពចំនួន.........។

| |
|---|
| **សេចក្ដីពន្យល់៖** ទិន្នន័យខាងលើនេះស្រង់ចេញពីកូឡោនទី៨ពីតារាងក្នុងចំណុច១.១២នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

**១.១៣-ការចុះឈ្មោះបោះឆ្នោតនិងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត**

ផ្អែកតាមច្បាប់ជ្រើសតាំងតំណាងរាស្ត្រ បទបញ្ញានិងនីតិវិធីនៃការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ រដ្ឋបាលឃុំ សង្កាត់ត្រូវបានប្រតិភូកម្មលើការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំនៅឃុំ សង្កាត់។ ជាក់ស្ដែង ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មីតាមប្រព័ន្ធកុំព្យូទ័រនៅឃុំ សង្កាត់.........មានចំនួន.....................។

| |
|---|
| **សេចក្ដីពន្យល់៖** ទិន្នន័យខាងលើនេះស្រង់ចេញពីកូឡោនទី៧ពីតារាងក្នុងចំណុច១.១៣នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

**១.១៤-ការផ្ដល់សេវារដ្ឋបាល**

នៅថ្នាក់ឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់ជាច្រកចេញចូលតែមួយសម្រាប់ផ្ដល់សេវារដ្ឋបាលជូនប្រជាជនស្របតាមបែបបទនិងនីតិវិធីនៃការផ្ដល់សេវារដ្ឋបាល។ ជាក់ស្ដែង ក្នុងអំលុង៥ឆ្នាំនៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់.....................បានផ្ដល់សេវារដ្ឋបាលចំនួន.................... និងទទួលបានចំណូលពីសេវានេះចំនួន.........................រៀល។

| |
|---|
| **សេចក្ដីពន្យល់៖** ទិន្នន័យខខាងលើនេះស្រង់ចេញពីកូឡោនទី៧ពីតារាងក្នុងចំណុច១.១៤នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

**១.១៥-ការងារសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ**

..............................................................................................................................

..............................................................................................................................

.............................................................................................................................។

| |
|---|
| **សេចក្ដីពន្យល់៖** ចំណុចខាងលើនេះស្រង់ដោយសង្ខេបពីចំណុច១.១៥នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

**១.១៦-ការងារសេដ្ឋកិច្ច សង្គមកិច្ច**

..............................................................................................................................

..............................................................................................................................

.........................................................................................................................។

| |
|---|
| **សេចក្ដីពន្យល់៖** ចំណុចខាងលើនេះស្រង់ដោយសង្ខេបពីចំណុច១.១៦នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។ |

**១.១៧-ការងារគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន វប្បធម៌ បេតិកភណ្ឌជាតិ**

..............................................................................................................................

.......................................................................................................................................

......................................................................................................................................។

**សេចក្តីពន្យល់៖** ចំណុចខាងលើនេះស្រង់ដោយសង្ខេបពីចំណុច១.១៧នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

## ១.១៨-ការងារសហការជាមួយអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន

.......................................................................................................................................

.......................................................................................................................................

......................................................................................................................................។

**សេចក្តីពន្យល់៖** ចំណុចខាងលើនេះស្រង់ដោយសង្ខេបពីចំណុច១.១៨នៃរបាយការណ៍ស្តីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

# ផ្នែកទី២

# បញ្ហាប្រឈម ដំណោះស្រាយ និងសំណូមពរ

## ២.១-បញ្ហាប្រឈម និងដំណោះស្រាយ

ទន្ទឹមនឹងសមិទ្ធផលការងារសំខាន់ៗនៅក្នុងអាណត្តិទី៤របស់ក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់.................បានជួបប្រទះបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តតួនាទីនិងភារកិច្ចរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចាត់ចែងនិងការផ្តល់សេវាសាធារណៈសំដៅលើកកម្ពស់ជីវភាពរបស់ប្រជាជនក្នុងកិច្ចអភិវឌ្ឍឃុំ សង្កាត់។ ក្នុងអាណត្តិនេះ រដ្ឋបាលឃុំ សង្កាត់...........មានបញ្ហាប្រឈមសំខាន់ៗ ហើយបានដោះស្រាយ និងសំណូមពរមួយចំនួន ដូចខាងក្រោម៖

ក-បញ្ហាប្រឈមសំខាន់ៗ

- ..............................................................................................................
- ..............................................................................................................
- ..............................................................................................................
- ..............................................................................................................។

ខ-ដំណោះស្រាយ

១-..............................................................................................................

២-..............................................................................................................

៣-..............................................................................................................

៤-..............................................................................................................

៥-..............................................................................................................

..............................................................................................................

..........................................................................។

**សេចក្ដីពន្យល់៖** បញ្ហាប្រឈមនិងដំណោះស្រាយខាងលើនេះ អាចស្រង់ដោយសង្ខេបពីតារាងក្នុងចំណុច២.១នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

**២.២-យោបល់និងសំណូមពរ**

បញ្ហាប្រឈមនិងដំណោះស្រាយខាងលើនេះ គឺជាបទពិសោធក្នុងកិច្ចអភិវឌ្ឍឃុំ សង្កាត់ នៅក្នុងអាណត្តិរបស់ក្រុមប្រឹក្សាបន្តទៀត។ ជាមួយគ្នានេះ រដ្ឋបាលឃុំ សង្កាត់..........មានយោបល់និងសំណូមពរមួយចំនួន ដូចខាងក្រោម៖

១-.................................................................................................................

២-.................................................................................................................

៣-.................................................................................................................

៤-.................................................................................................................

.....................................................................................................................

..................................................................................................................។

**សេចក្ដីពន្យល់៖** យោបល់និងសំណូមពរទាំងនេះ អាចស្រង់ដោយសង្ខេបពីចំណុច២.២នៃរបាយការណ៍ស្ដីពីសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤។

របាយការណ៍សង្ខេបសម្រាប់ផ្ទេរក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិចាស់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិថ្មី ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំ........លើកទី........របស់ក្រុមប្រឹក្សាឃុំ សង្កាត់........នាថ្ងៃទី.......ខែ............. ឆ្នាំ២០២២៕

**មេឃុំ ចៅសង្កាត់**

**ចម្លងជូន÷**

-រដ្ឋបាលរាជធានី ខេត្តសាមី

-សាលាក្រុង ស្រុក ខណ្ឌសាមី

-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី១

រាជធានី ខេត្ត......................

ក្រុង ស្រុក ខណ្ឌ.................

រដ្ឋបាលឃុំ សង្កាត់.............

# ស្ថិតប្រជាពលរដ្ឋ

គិតត្រឹមថ្ងៃទី........ខែ..............ឆ្នាំ២០២២

| ល.រ. | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ប្រជាពលរដ្ឋទូទៅ | | | | | | ប្រជាពលរដ្ឋ១៨ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | | | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | | |
| | | សរុប | អចិន្ត្រៃយ៍ | ប.អាសន្ន | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | | | | |

ថ្ងៃ.................... ខែ.............. ឆ្នាំ.............. ព.ស.២៥៦...

........................... ថ្ងៃទី.............. ខែ.............. ឆ្នាំ២០២២

**មេឃុំ ឬចៅសង្កាត់អាណត្តិចាស់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី២

រាជធានី ខេត្ត.....................

ក្រុង ស្រុក ខណ្ឌ.................

រដ្ឋបាលឃុំ សង្កាត់.................

## បញ្ជីក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ បុគ្គលិក ជនបង្គោល និងថ្នាក់ដឹកនាំភូមិ

## គិតត្រឹមថ្ងៃទី........ខែ..........ឆ្នាំ២០២២

ក)-ក្រុមប្រឹក្សា

| ល.រ. | នាមត្រកូលនិងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | កម្រិតវប្បធម៌ | មុខតំណែង | ថ្ងៃខែឆ្នាំចូលកាន់មុខតំណែង | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១ | | | | | មេឃុំ ឬចៅសង្កាត់ | | |
| ២ | | | | | ជំទប់ទី១ ឬចៅសង្កាត់រងទី១ | | |
| ៣ | | | | | ជំទប់ទី១ ឬចៅសង្កាត់រងទី២ | | |
| ៤ | | | | | សមាជិក | | |
| ៥ | | | | | សមាជិក | | |
| ៦ | | | | | សមាជិក | | |
| ៧ | | | | | សមាជិក | | |
| ៨ | | | | | សមាជិក | | |
| ៩ | | | | | សមាជិក | | |
| ១០ | | | | | សមាជិក | | |
| ១១ | | | | | សមាជិក | | |

ខ)-គណៈកម្មាធិការ និងគណៈកម្មការ

| ល.រ. | ឈ្មោះគណៈកម្មាធិការ ឬគណៈកម្មការ | ចំនួនសមាជិក | | ឈ្មោះប្រធានគណៈកម្មាធិការ ឬគណៈកម្មការ | លេខ និងកាលបរិច្ឆេទនៃសេចក្តីសម្រេចបង្កើត | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ស្រី | | | |
| ១ | គណៈកម្មាធិការកសាងផែនការ និងថវិកា | | | | | |
| ២ | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ | | | | | |
| ៣ | គណៈកម្មការលទ្ធកម្ម | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

គ)-បុគ្គលិក (បុគ្គលិកជាមន្ត្រីក្របខណ្ឌរដ្ឋ និងបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ)

| ល.រ. | នាមត្រកូលនិងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | កម្រិតវប្បធម៌ | ប្រភេទបុគ្គលិក | មុខតំណែង | ថ្ងៃខែឆ្នាំ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ចូលបម្រើការងារ | បញ្ចប់ពីការងារ |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

**ឃ)-ជនបង្គោល**

| ល.រ. | នាមត្រកូលនិងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំ កំណើត | កម្រិតវប្បធម៌ | មុខតំណែង | លេខ និងកាលបរិច្ឆេទនៃ សេចក្ដីសម្រេច | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**ង)-ថ្នាក់ដឹកនាំភូមិ**

| ល.រ. | នាមត្រកូលនិងនាមខ្លួន | ភេទ | មុខតំណែង | លេខ និងកាលបរិច្ឆេទនៃ សេចក្ដីសម្រេច | ឈ្មោះភូមិ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | មេភូមិ | | | |
| | | | អនុប្រធានភូមិ | | | |
| | | | ជំនួយការភូមិ | | | |
| | | | មេភូមិ | | | |
| | | | អនុប្រធានភូមិ | | | |
| | | | ជំនួយការភូមិ | | | |
| | | | | | | |
| | | | | | | |

ថ្ងៃ.................... ខែ.............. ឆ្នាំ............ ព.ស.២៥៦..

...................... ថ្ងៃទី.............. ខែ.............. ឆ្នាំ២០២២

**មេឃុំ ឬចៅសង្កាត់អាណត្តិចាស់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៣

រាជធានី ខេត្ត.....................

ក្រុង ស្រុក ខណ្ឌ.................

រដ្ឋបាលឃុំ សង្កាត់..................

# បញ្ជីគម្រោងរបស់រដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០២២

គិតត្រឹមថ្ងៃទី........ខែ..............ឆ្នាំ២០២២

ក)-គម្រោងឃុំ សង្កាត់ដែលពុំទាន់បានធ្វើលទ្ធកម្ម

| ល.រ. | ឈ្មោះគម្រោង | លទ្ធផលគម្រោង | តម្លៃប៉ាន់ស្មាន(គិតជារៀល) | ផ្សេងៗ |
| --- | --- | --- | --- | --- |
| | | | | |
| | | | | |
| | | | | |
| សរុប | | | | |

ខ)-គម្រោងឃុំ សង្កាត់ដែលបានធ្វើលទ្ធកម្មរួច តែមិនទាន់បានចុះកិច្ចសន្យា

| ល.រ. | ឈ្មោះគម្រោង | លទ្ធផលគម្រោង | តម្លៃដេញថ្លៃឈ្នះ (គិតជារៀល) | ឈ្មោះក្រុមហ៊ុន ឬបុគ្គលដែលដេញថ្លៃឈ្នះ | ផ្សេងៗ |
| --- | --- | --- | --- | --- | --- |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | |

គ)-គម្រោងឃុំ សង្កាត់ដែលបានចុះកិច្ចសន្យារួច

| ល.រ. | ឈ្មោះកិច្ចសន្យា និងលេខកិច្ចសន្យា | លទ្ធផលកិច្ចសន្យា | តម្លៃកិច្ចសន្យា (គិតជារៀល) | ឈ្មោះក្រុមហ៊ុន ឬបុគ្គល ដែលបានចុះកិច្ចសន្យា | ចំនួនភាគរយ ដែលបានអនុវត្ត |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | |

ថ្ងៃ.................... ខែ.............. ឆ្នាំ................ ព.ស.២៥៦..

........................... ថ្ងៃទី.............. ខែ.............. ឆ្នាំ២០២២

**មេឃុំ ឬចៅសង្កាត់អាណត្តិចាស់**

ឧបសម្ព័ន្ធទី៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានី ខេត្ត.....................**

**ក្រុង ស្រុក ខណ្ឌ................**

រដ្ឋបាលឃុំ សង្កាត់.............

# បញ្ជីកិច្ចសន្យានានាដែលពាក់ព័ន្ធនឹងរដ្ឋបាលឃុំ សង្កាត់

គិតត្រឹមថ្ងៃទី.....ខែ........ឆ្នាំ២០២២

**ក)-កិច្ចសន្យាដែលរដ្ឋបាលឃុំ សង្កាត់ជាភាគី "ក"**

| ល.រ. | ឈ្មោះកិច្ចសន្យា និងលេខកិច្ចសន្យា | កម្មវត្ថុនៃកិច្ចសន្យា | ឈ្មោះ និងអាសយដ្ឋានរបស់ភាគី "ខ" | កាលបរិច្ឆេទ | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | ចុះកិច្ចសន្យា | បញ្ចប់ | |
| | | | | | | |
| | | | | | | |

**ខ)-កិច្ចសន្យាដែលរដ្ឋបាលឃុំ សង្កាត់ជាភាគី "ខ"**

| ល.រ. | ឈ្មោះកិច្ចសន្យា និងលេខកិច្ចសន្យា | កម្មវត្ថុនៃកិច្ចសន្យា | ឈ្មោះ និងអាសយដ្ឋានរបស់ភាគី "ក" | កាលបរិច្ឆេទ | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | ចុះកិច្ចសន្យា | បញ្ចប់ | |
| | | | | | | |
| | | | | | | |

**កំណត់សម្គាល់៖**

- បញ្ជីនេះកត់ត្រាចំពោះតែកិច្ចសន្យាដែលមានការពាក់ព័ន្ធនឹងឃុំ សង្កាត់ ហើយមិនទាន់បានបញ្ចប់ប៉ុណ្ណោះ។
- ឃុំ សង្កាត់ជាភាគី "ក" គឺឃុំ សង្កាត់ជាអ្នកជួលអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់។
- ឃុំ សង្កាត់ជាភាគី "ខ" គឺឃុំ សង្កាត់ត្រូវបានគេស្នើចុះកិច្ចសន្យាសម្រាប់ការងារអ្វីមួយ។

ថ្ងៃ..................... ខែ.............. ឆ្នាំ.............. ព.ស.២៥៦...

.......................... ថ្ងៃទី.............. ខែ.............. ឆ្នាំ២០២២

**មេឃុំ ឬចៅសង្កាត់អាណត្តិចាស់**

ឧបសម្ព័ន្ធ៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត......................

ក្រុង ស្រុក ខណ្ឌ.................

រដ្ឋបាលឃុំ សង្កាត់..................

## ស្ថានភាពថវិកានិងសាច់ប្រាក់របស់រដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០២២

គិតត្រឹមថ្ងៃទី.....ខែ........ឆ្នាំ២០២២

### ក)-ស្ថានភាពថវិកា

| ចំណូល | អនុម័ត | អនុវត្តជាក់ស្តែង | នៅសល់ |
|---|---|---|---|
| ចំណូលសារពើពន្ធ | | | |
| ចំណូលមិនមែនសារពើពន្ធ | | | |
| សរុប | | | |

| ចំណាយ | អនុម័ត | អនុវត្តជាក់ស្តែង | នៅសល់ |
|---|---|---|---|
| ចំណាយចរន្ត | | | |
| ចំណាយមូលធន | | | |
| *សរុប* | | | |

### ខ)-ស្ថានភាពសាច់ប្រាក់រង្វាន់ទេយ្យបុរេប្រទាន

| ល.រ. | ការបរិយាយ | ទឹកប្រាក់ចំណូល | ទឹកប្រាក់ចំណាយ | ទឹកប្រាក់នៅសល់ |
|---|---|---|---|---|
| ១ | ការដកប្រាក់រង្វទេយ្យបុរេប្រទានជុំដំបូង ឬជុំទី១ | | | |
| ២ | ការបំពេញរង្វទេយ្យបុរេប្រទានជុំទី......... | | | |
| ៣ | ការបំពេញរង្វទេយ្យបុរេប្រទានជុំទី............ | | | |
| ៤ | ........................... | | | |
| ៥ | | | | |
| សរុប | | | | |

### គ)-ស្ថានភាពសាច់ប្រាក់ផ្សេងៗទៀត ក្រៅពីរង្វទេយ្យបុរេប្រទាន

| ល.រ. | ការបរិយាយ | ទឹកប្រាក់ចំណូល | ទឹកប្រាក់ចំណាយ | ទឹកប្រាក់នៅសល់ |
|---|---|---|---|---|
| ១ | កម្រៃសេវារដ្ឋបាល | | | |
| ២ | ទុនចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន | | | |
| ៣ | ............................ | | | |
| ៤ | ............................ | | | |
| សរុប | | | | |

**ឃ)-ស្ថានភាពសាច់ប្រាក់នៅធនាគារឯកជន**

| ល.រ. | ឈ្មោះធនាគារឯកជន | លេខគណនី | ទឹកប្រាក់ចំណូល | ទឹកប្រាក់ចំណាយ | ទឹកប្រាក់នៅសល់ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | |

ថ្ងៃ.................. ខែ............ ឆ្នាំ................ ព.ស.២៥៦..

............................ ថ្ងៃទី............ ខែ............ ឆ្នាំ២០២២

**មេឃុំ ឬចៅសង្កាត់អាណត្តិចាស់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធ៦

រាជធានី ខេត្ត.....................

ក្រុង ស្រុក ខណ្ឌ.................

រដ្ឋបាលឃុំ សង្កាត់.............

## បញ្ជីទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់

គិតត្រឹមថ្ងៃទី.......ខែ............ឆ្នាំ២០២២

| ល.រ. | ឈ្មោះសម្ភារៈ បរិក្ខារ | ប្រភេទ | លេខសម្គាល់ | កាលបរិច្ឆេទ ទិញ ឬទទួល | តម្លៃដើម | ទីតាំង | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ថ្ងៃ.................. ខែ.............. ឆ្នាំ............... ព.ស.២៥៦..

.......................... ថ្ងៃទី.............. ខែ.............. ឆ្នាំ២០២២

**មេឃុំ ឬចៅសង្កាត់អាណត្តិចាស់**